តើអ្នកត្រូវការជំនួយក្នុងការបង់ប្រាក់វិក្កយបត្រអគ្គិសនីរបស់អ្នកទេ?

ក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីរបស់អ្នកផ្តល់ជូនការបញ្ចុះតម្លៃវិក្កយបត្រ ការបន្ធូរបន្ថយ និងកម្មវិធីបង់ប្រាក់ដើម្បីជួយគ្របគ្រងចំណាយប្រចាំខែ។



ធ្វើឱ្យវិក្កយបត្រប្រចាំខែមានភាពមានស្ថេរភាព និងអាចទុកចិត្តបាន



សងប្រាក់វិក្កយបត្រដែលនៅសល់



បន្តយចំណាយវិក្កយបត្រប្រចាំខែរបស់អ្នក

តើអ្នកចង់បង់ប្រាក់វិក្កយបត្រដូចគ្នារៀងរាល់ខែទេ?

កម្មវិធីបង់ប្រាក់ស្មើគ្នា៖
អ្នកអាចបែងចែកចំណាយវិក្កយបត្រប្រចាំឆ្នាំជាការបង់ប្រាក់ស្មើគ្នារៀងរាល់ខែ។
ចំនួនប្រាក់អាចត្រូវបានកែប្រែជាប្រចាំ ដោយផ្អែកលើការប្រើប្រាស់ជាក់ស្តែង។

តើអ្នកមានវិក្កយបត្រដែលនៅមិនទាន់បង់ទេ?

កម្មវិធីបង់ប្រាក់តាមដំណាក់កាល៖
អ្នកអាចបង់ប្រាក់សម្រាប់ចំនួនប្រាក់ដែលនៅសល់ជាបន្តបន្ទាប់តាមរយៈពេល ដោយមិនគិតពីកម្រិតប្រាក់ចំណូលរបស់អ្នក។

តើគ្រួសាររបស់អ្នកមានសិទ្ធិទទួលបានជំនួយបន្ថែមដែរឬទេ?

បើប្រាក់ចំណូលរបស់គ្រួសាររបស់អ្នកស្ថិតនៅក្នុងកម្រិតដែលបានកំណត់ខាងក្រោម អ្នកអាចទទួលបានអត្រាបញ្ចុះតម្លៃ និងកម្មវិធីបន្ធូរបំណុលតាមរយៈក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនី។ សូមទាក់ទងក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីរបស់អ្នក ដើម្បីចុះឈ្មោះ។

ចំនួនសមាជិកគ្រួសារ	1	2	3	4	5	6	7	8
ប្រាក់ចំណូលអតិបរមា	$51,777	$67,709	$83,641	$99,573	$115,504	$131,436	$134,423	$137,410

ប្រសិនបើអ្នកត្រូវការការបន្ធូរប្រាក់វិក្កយបត្រប្រចាំខែ អ្នកអាចទទួលបានការបញ្ចុះតម្លៃលើវិក្កយបត្រអគ្គិសនីសរុបរបស់អ្នករៀងរាល់ខែ។
ប្រសិនបើអ្នកកំពុងចូលរួមក្នុងកម្មវិធី SNAP, MassHealth, HEAP
ឬកម្មវិធីជំនួយផ្សេងទៀតដែលមានសិទ្ធិ
អ្នកប្រហែលជាកំពុងទទួលបានអត្រាបញ្ចុះតម្លៃរួចហើយ។
ការបញ្ចុះតម្លៃតាមក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនី៖

- National Grid៖ 32%–71%
- Eversource៖ 42%
- Unitil៖ 40%

ប្រសិនបើអ្នកមានវិក្កយបត្រដែលនៅមិនទាន់បង់
ក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីរបស់អ្នកផ្តល់ជូនកម្មវិធីបន្ធូរបំណុល។
រៀងរាល់ខែដែលអ្នកបង់ប្រាក់វិក្កយបត្របច្ចុប្បន្នតាមពេលវេលា
ក្រុមហ៊ុននឹងកាត់បន្ថយភាគរយមួយនៃប្រាក់ដែលអ្នកនៅជំពាក់។ អ្នកអាចចុះឈ្មោះបាន ប្រសិនបើ៖

- ☑ អ្នកកំពុងទទួលបានអត្រាបញ្ចុះតម្លៃ
- ☑ ចំនួនប្រាក់ដែលអ្នកនៅជំពាក់លើសពី $300
- ☑ ចំនួនប្រាក់ដែលអ្នកនៅជំពាក់មានរយៈពេលលើសពី 60 ថ្ងៃ

Eversource West៖ (877) 659-6326
Eversource East៖ (800) 592-2000
National Grid៖ (800) 322-3223
Unitil៖ (888) 301-7700